# សេចក្តីប្រកាសព័ត៌មាន

## សេចក្តីថ្លែងការណ៍របស់លោកសាស្រ្តាចារ្យ សុរិយា ប្រាសាទ ស៊ូប៊ែឌី អ្នករាយការណ៍ពិសេសអង្គការសហប្រជាជាតិស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា

រាជធានីភ្នំពេញ ថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១២

ខ្ញុំហៀបនឹងបញ្ចប់ដំណើរបេសកកម្មស្វែងរកការពិតខាងសិទ្ធិមនុស្សលើកទីប្រាំពីររបស់ខ្ញុំ នៅកម្ពុជាហើយ។ បេសកកម្មនេះ បានផ្តោតសំខាន់លើការវាយតំលៃអំពីផលប៉ះពាល់សិទ្ធិមនុស្សដោយសម្បទានដីសេដ្ឋកិច្ច និងសម្បទានដីដទៃទៀតនៅកម្ពុជា។ នៅក្នុងអំឡុងពេលបំពេញបេសកកម្មរបស់ខ្ញុំ ខ្ញុំបានខិតខំធ្វើការវាយតំលៃផងដែរអំពីវឌ្ឍនភាពនៃការអនុវត្តន៍អនុសាសន៍ទាំងឡាយ ដែលមាននៅក្នុងរបាយការណ៍កន្លងមករបស់ខ្ញុំដាក់ជូនក្រុមប្រឹក្សាសិទ្ធិមនុស្ស។ ខ្ញុំបានឆ្លៀតឱកាសនេះផងដែរ ដើម្បីបន្តឃ្លាំមើល និងដោះស្រាយបញ្ហាសិទ្ធិមនុស្សដែលនៅបន្តមាននៅក្នុងប្រទេសកម្ពុជា មានជាអាទិ៍ សេរីភាពក្នុងការបញ្ចេញមតិ និងសេរីភាពក្នុងការជួបប្រជុំ ការការពារអ្នកការពារសិទ្ធិមនុស្ស និងការរៀបចំសំរាប់ការបោះឆ្នោតនៅពេលខាងមុខ (ដែលខ្ញុំបានផ្តោតទៅលើបញ្ហាទាំងអស់នេះនៅក្នុងដំណើរបេសកកម្មរបស់ខ្ញុំកាលពីលើកមុខ)។

នៅក្នុងពេលបំពេញបេសកកម្មនេះ ខ្ញុំមានលទ្ធភាពធ្វើទស្សនកិច្ចទៅកាន់ខេត្តរតនគីរី ស្ទឹងត្រែង និងក្រចេះ។ នៅក្នុងខេត្តនីមួយៗ ខ្ញុំបានជួបប្រជុំជាមួយសហគមន៍ទាំងឡាយដែលរងផលប៉ះពាល់ដោយសម្បទានដី ព្រមទាំងជួបជាមួយអាជ្ញាធរខេត្តផងដែរ។ ខ្ញុំបានខិតខំដើម្បីទាក់ទងជាមួយបណ្តាក្រុមហ៊ុនសាជីវកម្មផ្សេងៗពាក់ព័ន្ធដែលទទួលបានដីសម្បទាន។ ខ្ញុំនឹងបន្តកិច្ចខិតខំតទៅទៀត ដើម្បីធ្វើទំនាក់ទំនងជាមួយក្រុមហ៊ុនសាជីវកម្មទាំងនេះ ដែលជាតួអង្គសំខាន់ក្នុងការប្រតិបត្តិការដីសម្បទាន និងជាតួអង្គសំខាន់ដែលទទួលអត្ថប្រយោជន៍ពីសម្បទានទាំងនេះ។ ខ្ញុំមានលទ្ធភាពអាចជួបផងដែរជាមួយតួអង្គសង្គមស៊ីវិល រដ្ឋមន្រ្តីក្រសួងបរិស្ថាន ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ តំណាងអង្គទូត និងអ្នកផ្តល់ជំនួយនានា ព្រមទាំងក្រុមអង្គការសហប្រជាជាតិប្រចាំប្រទេស។ ខ្ញុំសោកស្តាយដែលមិនបានជួបជាមួយក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ ព្រោះថាក្រសួងនេះ ជាស្ថាប័នរដ្ឋាភិបាលមួយសំខាន់ពាក់ព័ន្ធនឹងការផ្តល់ដីសម្បទាន។

ខាងក្រោមនេះគឺជាអ្វីដែលខ្ញុំបានគិត និងបានរកឃើញជាបឋម និងសេចក្តីសង្ខេបពីបញ្ហាដែលបាននាំមកនូវការទាក់ទាញការយកចិត្តទុកដាក់របស់ខ្ញុំក្នុងទស្សនកិច្ចលើកនេះ។ ខ្ញុំនឹងធ្វើការវាយតម្លៃទៅលើព័ត៌មាន

មួយចំនួនធំដែលខ្ញុំបានទទួល និងរៀបចំសរសេររបាយការណ៍ដាក់ជូនក្រុមប្រឹក្សាសិទ្ធិមនុស្ស ដើម្បីធ្វើការពិចារណា ក្នុងសម័យប្រជុំរបស់ខ្លួន ក្នុងខែកញ្ញា ឆ្នាំ២០១២ ខាងមុខនេះ។

ខ្ញុំដឹងថាប្រទេសកម្ពុជា កំពុងធ្វើការអភិវឌ្ឍន៍ប្រទេសរបស់ខ្លួន ដែលមានបំណងប្រើប្រាស់ដី និងធនធានធម្មជាតិ សំរាប់អភិវឌ្ឍន៍ប្រទេស ហើយនិងនាំមកនូវវិបុលភាពជូនប្រជាពលរដ្ឋរបស់ខ្លួន។ ខ្ញុំបានដឹងផងដែរអំពីកាលៈទេសៈនៃប្រវត្តិសាស្ត្ររបស់ប្រទេសកម្ពុជា មានរួមទាំងនយោបាយរបស់របបខ្មែរក្រហមផងដែរ ដែលនាំមកនូវការរីករាលដាលនៃជំលោះដីធ្លី ដែលរាជរដ្ឋាភិបាលកំពុងព្យាយាមចាត់ចែងដោះស្រាយ។ ខ្ញុំបានកត់សំគាល់ផងដែរថា មានកម្មវិធីផ្តល់ដីសម្បទានសង្គមកិច្ច ដែលបានផ្តល់ដីជូនដល់ប្រជាពលរដ្ឋក្រីក្រដែលគ្មានដី។ អ្វីដែលបាននិយាយនេះ គឺខ្ញុំមានទស្សនៈថា ដីសម្បទានគប្បីផ្តល់ និងគ្រប់គ្រង ក្រោមគោលនយោបាយ និងច្បាប់ ដោយមានរួមទាំងការគោរពសិទ្ធិមនុស្ស ជាពិសេសសិទ្ធិជនជាតិដើមភាគតិច។

ប្រទេសកម្ពុជាមាននូវក្របខ័ណ្ឌច្បាប់សមស្របជាច្រើនសំរាប់គ្រប់គ្រងលើ ការផ្តល់ និងការចាត់ចែងដីសម្បទាន ដែលក្នុងចំណោមលិខិតបទដ្ឋានគតិយុត្តផ្សេងៗ រួមមាន ច្បាប់ភូមិបាលឆ្នាំ២០០១ អនុក្រឹត្យឆ្នាំ២០០៥ ច្បាប់ស្តីពីតំបន់ការពារធម្មជាតិឆ្នាំ២០០៨។ ខ្ញុំក៏បានទទួលដំណឹងថា រាជរដ្ឋាភិបាលកំពុងតែធ្វើការពិចារណាទៅលើសេចក្តីព្រាងច្បាប់ថ្មីមួយទៀតគឺសេចក្តីព្រាងច្បាប់ស្តីពីការវាយតម្លៃផលប៉ះពាល់បរិស្ថាន។ ដូចខ្ញុំធ្លាប់បានធ្វើការកត់សំគាល់កន្លងមកពាក់ព័ន្ធនឹងវិស័យផ្សេងៗនៅកម្ពុជាថា ការបង្កើតអោយមានលិខិតបទដ្ឋានគតិយុត្តនៅលើក្រដាសគឺជាចំណែកមួយ រីឯការយកលិខិតបទដ្ឋានគតិយុត្តទាំងនោះមកអនុវត្តជាក់ស្តែងគឺជាចំណែកមួយទៀត។ ខ្ញុំបានទទួលព័ត៌មានជាបន្តបន្ទាប់ថា ក្នុងករណីមួយចំនួនលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការផ្តល់ដីសម្បទាន មិនត្រូវបានយកអនុវត្តអោយបានពេញលេញទេ។

ចរិកលក្ខណៈនៃសម្បទាននានា មានពាក់ព័ន្ធនឹងតួនាទីរបស់វិស័យឯកជន ដែលនៅក្នុងបរិបទនៃអណត្តិការងាររបស់ខ្ញុំនោះ គឺមានន័យថា តួនាទីរបស់វិស័យឯកជនក្នុងការគោរពសិទ្ធិមនុស្ស។ គឺជាការជាក់ច្បាស់ណាស់ថា រាជរដ្ឋាភិបាលមានការទទួលខុសត្រូវជាចម្បងក្នុងការគោរព ការពារ និងអនុវត្តសិទ្ធិទាំងឡាយសម្រាប់ប្រជាពលរដ្ឋរបស់ខ្លួន។ ទោះជាយ៉ាងណាក្តី ធុរកិច្ច(អាជីវកម្ម) ក៏មានតួនាទីផងដែរក្នុងការគោរពសិទ្ធិមនុស្ស។ នៅឆ្នាំ ២០១១ ក្រុមប្រឹក្សាសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិបានអនុម័តយល់ព្រមនូវគោលការណ៍ណែនាំស្តីពីធុរកិច្ច និងសិទ្ធមនុស្ស ។ គោលការណ៍ទាំងនេះ បង្កើននូវកាតព្វកិច្ចផ្នែកសិទ្ធិមនុស្សដែលមានស្រាប់ រាប់បញ្ចូលទាំងកាតព្វកិច្ចទាំងឡាយដែលមានចែងនៅក្នុងសន្ធិសញ្ញាអន្តរជាតិនានាដែលកម្ពុជាបានផ្តល់សច្ចាប័ន។ បទដ្ឋានទាំងនេះ អាចដាក់អោយអនុវត្តបានទាំងចំពោះ ក្រុមហ៊ុនខ្មែរ និងបរទេសដែលកំពុងតែប្រតិបត្តិការនៅក្នុងប្រទេសកម្ពុជា ដោយមិនគិតដល់ វិស័យ ទំហំ ឬរចនាសម្ព័ន្ធ ហើយក៏មាន

កំណត់អំពីភារកិច្ចរបស់រដ្ឋាភិបាលក្នុងការអនុវត្តពិនិត្យមើលលើសកម្មភាពទាំងឡាយរបស់ក្រុមហ៊ុនផងដែរ។

អនុញ្ញាតិអោយខ្ញុំត្រឡប់មកធ្វើការឆ្លុះបញ្ចាំងអំពីស្ថានភាពបច្ចុប្បន្ននៃដីសម្បទាននៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ដៃគូសន្ទនាមួយចំនួនរបស់ខ្ញុំ ក្នុងកំឡុងពេលបេសកកម្មនេះ បានគូសបញ្ជាក់អំពីផលប្រយោជន៍ផ្នែកសង្គម និងសេដ្ឋកិច្ច ដែលទទួលបានពីដីសម្បទាននៅក្នុងប្រទេសកម្ពុជា។ ពួកគេបានបញ្ជាក់ពីការបង្កើតនូវការងារ ការប្រមូលពន្ធ និង ផលប្រយោជន៍ពាក់ព័ន្ធផ្សេងៗទៀតសម្រាប់សហគមន៍នានានៅក្នុងតំបន់សម្បទាន ដែលមានដូចជា ផ្លូវ មណ្ឌលសុខភាព និងសាលារៀនថ្មីជាដើម ។

ទោះជាយ៉ាងណាក៏ដោយ គូសន្ទនាមួយចំនួនផ្សេងទៀត បង្ហាញពីការយល់ឃើញខុសគ្នា។

បុគ្គលមួយចំនួនដែលខ្ញុំបានជួប បានរៀបរាប់ថា ជាប្រព័ន្ធមួយដែលតម្លាភាពកម្រិតទាបបំផុត មានន័យថាសហគមន៍ទាំងឡាយ តែងតែមិនដឹងថាសម្បទានក្នុងតំបន់ពួកគេនោះ ត្រូវបានផ្តល់នៅពេលណា និងដោយរបៀបណាទេ។ ម៉្យាងទៀត ពួកគេមិនដឹងសោះដែរថា សម្បទានត្រូវបានផ្តល់ទៅក្រុមហ៊ុនចំនួនប៉ុន្មាន ក្រុមហ៊ុនណា ក៏ដូចជាពត៌មានរបស់ក្រុមហ៊ុនថាតើជាក្រុមហ៊ុនបរទេស ឬក្រុមហ៊ុនជាតិ ឬករណីខ្លះ ពួកគេមិនស្គាល់សូម្បីតែឈ្មោះរបស់ក្រុមហ៊ុនផងក៏មាន។ ការវាយតម្លៃផ្ទាល់ខ្លួនរបស់ខ្ញុំ បញ្ជាក់ពីស្ថានភាពនេះ។ ការទទួលបាននូវពត៌មាន គឺជាកត្តាសំខាន់ខ្លាំងណាស់ ។

សហគមន៏បានប្រាប់ខ្ញុំផងដែរថា ពួកគេកម្រនឹងទទួលបានការពិគ្រោះយោបល់ ដែលធ្វើឡើងដោយអាជ្ញាធរ ឬក្រុមហ៊ុនដែលពាក់ព័ន្ធតាមវិធីដែលមានអត្ថន័យ (ឬជួនកាលមិនមានទាល់តែសោះ) អំពីផលប៉ះពាល់លើជីវភាពរស់នៅ និងជីវិតរបស់ពួកគេ តាមរយៈការផ្តល់ដីសម្បទាន។ នេះសបញ្ជាក់ថា ជាញឹកញាប់ គឺមិនមានទីកន្លែងសំរាប់ពួកគេលើកឡើងពីកង្វល់របស់ខ្លួន ដែលមានលក្ខណៈជារចនាសម្ព័ន្ធដែលមានស្រាប់ និងដែលមានអត្ថន័យនោះទេ ដោយសហគមន៏មួយចំនួនត្រូវមានកាតព្វកិច្ចក្នុងការរកដំណោះស្រាយតាមរយៈប្រពន្ធ័តុលាការ ការដាក់ញត្តិជូនអាជ្ញាធរថ្នាក់ខេត្ត និងថ្នាក់ជាតិ និងការដើរតវ៉ាតាមផ្លូវនានា។

ជាងនេះទៅទៀត ដូចដែលខ្ញុំបាននិយាយពីពេលមុន កំរិតនៃការតវ៉ាដែលជាប់ពាក់ព័ន្ធនឹងវិវាទដីធ្លី ជាញឹកញាប់តែងមានអំពើហឹង្សា ហើយវាជាបុព្វហេតុសំខាន់ ដែលខ្ញុំតែងតែព្រួយបារម្ភ។ ការតវ៉ាតែងតែបង្កើតនូវឧបសគ្គយ៉ាងសម្បើមសំរាប់អាជ្ញាធរ ជាពិសេសអាជ្ញាធរថ្នាក់ខេត្ត។ ប្រភេទនៃការតវ៉ាមានច្រើនបែប ជាឧទាហរណ៍ សហគមន៍ធ្វើការបិទផ្លូវ ដែលទង្វើនេះអាចប៉ះពាល់យ៉ាងខ្លាំងដល់អ្នកដទៃដែលមិនពាក់ព័ន្ធនឹងវិវាទ ។ បុគ្គលគ្រប់រូប មានសិទ្ធិក្នុងការតវ៉ា តែខ្ញុំសូមជំរុញទៅដល់អ្នកពាក់ព័ន្ធ មានដូចជា អាជ្ញាធរ ក្រុមហ៊ុន និងសហគមន៍ គួរព្យាយាមអោយអស់លទ្ធភាពបំផុត ក្នុងការបញ្ជៀសមិនអោយមានអំពើហិង្សា ក្នុងពេលមានការ

តវ៉ា។ ការសន្ទនា គឺជាគន្លឹះសំខាន់បំផុត។

ខ្ញុំកត់សំគាល់អំពីការតវ៉ាជាបន្តបន្ទាប់ ដើម្បីសុំអោយមានការយកចិត្តទុកដាក់លើបញ្ហានៃការបំផ្លិចបំផ្លាញបរិស្ថាន ដែលកើតឡើងដោយសារការគ្រប់គ្រងដីធ្លីមិនបានល្អពាក់ព័ន្ធនឹងការធ្វើសម្បទាន ការទាញយកប្រយោជន៍ពីធនធានធម្មជាតិដោយគ្មាននិរន្តរភាព និងការផ្តល់ដីសម្បទានធ្វើអោយប៉ះពាល់ដល់គម្របព្រៃឈើនូវបរិមាណដ៏ច្រើន។ ការទាមទារទាំងអស់នេះ សមនឹងទទួលបាននូវការយកចិត្តទុកដាក់ជាបន្ទាន់ពីអាជ្ញាធរ។

ជាគោលការណ៍ សម្បទានដីពុំគួរប៉ះពាល់លើដីឬអចលនទ្រព្យរបស់បុគ្គលឯកជន ឬរបស់សហគមន៍នានា នោះឡើយ។ រាជរដ្ឋាភិបាលកម្ពុជាបានប្រាប់ខ្ញុំថា រដ្ឋាភិបាលបានអនុវត្តគោលនយោបាយស្បែកខ្លា ដែលមានគោលដៅអនុញ្ញាតឲ្យសហគមន៍នានា រស់រានដោយសុខដុមជាមួយសម្បទាននានា ប៉ុន្តែខ្ញុំក៏ទទួលបានព័ត៌មាន ពីសហគមន៍នានាផងដែរថា ពេលខ្លះគោលនយោបាយនេះមិនសូវមានប្រសិទ្ធិភាពក្នុងការអនុវត្តន៍ ឬអនុវត្តបានតែក្នុងករណី ខ្លះៗប៉ុណ្ណោះ។ ខ្ញុំសូមជំរុញអាជ្ញាធរឲ្យធានាស្វែងរកដំណោះស្រាយដែលអនុវត្តកើត និងយុត្តិធម៌ ដើម្បីឲ្យសហគមន៍ និងសម្បទានអាចរួមរស់ជាមួយគ្នាដោយសុខដុម។ ប្រសិនបើសម្បទានិកស្វែងរកកាន់កាប់ដី និងអចលនទ្រព្យរបស់បុគ្គលឯកជន សិទ្ធិទទួលបានដំណោះស្រាយ គួរត្រូវយកទៅអនុវត្ត ហើយគេត្រូវតែផ្តល់សំណងសមស្រប។

ស្ថានការណ៍របស់ប្រជាពលរដ្ឋជនជាតិដើមភាគតិច មានសារៈសំខាន់ខ្លាំងណាស់ក្នុងបរិបទនេះ។ ខ្ញុំបានធ្វើទស្សនកិច្ចនៅសហគមន៍ជនជាតិដើមភាគតិចមួយ ហើយបានទទួលព័ត៌មានអំពីសហគមន៍ផ្សេងៗទៀតជាច្រើន។ ចំណងដ៏ពិសេសនៃប្រជាពលរដ្ឋជនជាតិដើមភាគតិចកម្ពុជានឹងដីរបស់ពួកគាត់ ត្រូវបានគេដឹង និងចងក្រងជាឯកសារយ៉ាងច្បាស់លាស់។ រាជរដ្ឋាភិបាលបានផ្តល់ការយកចិត្តជាពិសេសដល់ស្ថានភាពរបស់ពួកគេ ដោយបានបង្កើតឡើងនូវក្របខណ្ឌគតិយុត្តិជាក់លាក់មួយ ដើម្បីដោះស្រាយកម្មសិទ្ធិលើដីធ្លីរបស់ពួកគេ ហើយខ្ញុំសូមអបអរសាទរចំពោះការងារមួយនេះ។ ខ្ញុំសូមស្វាគមន៍ចំពោះការផ្តល់កម្មសិទ្ធិដីសមូហភាពបីដំបូងដល់សហគមន៍ប្រជាពលរដ្ឋជនជាតិដើមភាគតិច ហើយសូមជំរុញឲ្យបង្កើនល្បឿនលើដំណើរការផ្តល់កម្មសិទ្ធិបែបនេះដល់សហគមន៍ផ្សេងៗទៀត។ ទន្ទឹមគ្នានេះដែរ និងដរាបណាសហគមន៍ទាំងនេះ អាចទទួលបានកម្មសិទ្ធិដីធ្លីរបស់ពួកគេ ដីរបស់ជនជាតិដើមភាគតិចត្រូវបានការពារ និងធានារក្សាតាមច្បាប់ជាធរមាន។

រាល់គ្រប់សហគមន៍ទាំងអស់ ដែលខ្ញុំបានជួបប្រាស្រ័យទាក់ទង ព្រមទាំងសហគមន៍ផ្សេងៗច្រើនទៀត ដែលបានបញ្ជូនលិខិតជាលាយលក្ខណ៍អក្សរដល់ខ្ញុំ បានលើកបញ្ហានៃការប្រព្រឹត្តមិនត្រឹមត្រូវរបស់ក្រុមហ៊ុន ដែលទទួលបានសម្បទាននានា ឬអ្នកចុះកិច្ចសន្យាការបន្ត(អនុសម្បទានិក) របស់ពួកគេ។ បញ្ហាទាំងនោះ មានតាំងពីការទន្ទ្រានយកដី ការរឹបអូសសត្វពាហនៈ ការបំផ្លាញផ្ទះសំបែងនិងទ្រព្យសម្បត្តិ ការបំផ្លាញទីបញ្ចុះ

សព អំពើហិង្សាលើរូបកាយ និងការគម្រាមកំហែង រួមបញ្ចូលទាំងការប្រើប្រាស់អាវុធជាតិផ្ទុះប្រឆាំងបុគ្គល និងសហគមន៍នានា។ នៅក្នុងករណីខ្លះ អាជ្ញាធរបានដាក់កម្រិតឲ្យក្រុមហ៊ុនឲ្យទទួលខុសត្រូវចំពោះទង្វើរបស់ពួកគេ។ ជាទឡ្ហីករណ៍ ឧបទ្ទវហេតុបាញ់ប្រហារនៅក្រុមហ៊ុនសម្បទានTTY ក្នុងខេត្តក្រចេះកាលពីដើមឆ្នាំនេះ។ ទោះជាដូច្នេះក្តី មានករណីជាច្រើនដែលការរំលោភបំពានពីសំណាក់ក្រុមហ៊ុននានា នៅតែមាននិទណ្ឌភាព។

នៅក្នុងករណីមួយចំនួន ត្រូវបានគេអះអាងថា ស្ថានភាពនៃការប្រព្រឹត្តមិនត្រឹមត្រូវនេះ ត្រូវបានធ្វើឡើងមួយជំហ៊ានបន្ថែមទៀត ជាមួយភ្នាក់ងាររដ្ឋ (ពួកគេអាចជាមន្រ្តីខេត្ត មេព្រៃ ឬអង្គភាពនគរបាល និងយោធា) ដែលការពារក្រុមហ៊ុន និងដីសម្បទានរបស់ ពួកគេ។ ការអះអាងទាំងនេះ ដែលខ្ញុំមិនទាន់ផ្ទៀងផ្ទាត់ គឺមានលក្ខណៈធ្ងន់ធ្ងរ ហើយតម្រូវឲ្យមានការស៊ើបអង្កេតបន្ថែមទៀត។

ជាចុងក្រោយ ខ្ញុំបានជួបជាមួយអ្នកការពារសិទ្ធិមនុស្សមួយចំនួនដែលធ្វើការលើបញ្ហាដីសម្បទាន។ បុគ្គលទាំងនេះ ទទួលរងហានិភ័យយ៉ាងខ្លាំងក្នុងការបំពេញការងាររបស់ខ្លួន ហើយមានសិទ្ធិទទួលបាននូវការការពារពីរដ្ឋ។ ខ្ញុំសូមចូលរួមសោកស្តាយលោក ឈុត វុទ្ធី ដែលត្រូវបានសម្លាប់ជាមួយនឹង លោក អ៊ិន រតនាកាល ពីថ្ងៃទី២៦ ខែមេសា ឆ្នាំ ២០១២ នៅខេត្តកោះកុង។ ខ្ញុំ បានចូលរួមគោរពវិញ្ញាណក្ខន្ធលោកឈុតវុទ្ធីនៅកន្លែងផ្ទះរបស់គាត់ នៅឯខេត្តកណ្តាល ហើយបានចូលរួមរំលែកទុក្ខជាមួយបងស្រីរបស់គាត់អំឡុងពេលបេសកកម្មរបស់ខ្ញុំផងដែរ។ ខ្ញុំដឹងថា ការស៊ើបអង្កេតឧប្បត្តិហេតុនេះ កំពុងតែធ្វើឡើងដោយចៅក្រមស៊ើបសួរនៃតុលាការខេត្ត។ ខ្ញុំសង្ឃឹមថានឹងមានដំណោះស្រាយយ៉ាងឆាប់រហ័យ និងប្រកបដោយយុត្តិធម៌មួយទៅលើករណីនេះ។ ខ្ញុំសូមលើកឡើងថា នៅក្នុងករណីនេះ និងករណីផ្សេងៗទៀតក្នុងឆ្នាំ ២០១២ យើងបានឃើញមានការប្រើប្រាស់អាវុធប្រឆាំងនឹង អ្នកការពារសិទ្ធិមនុស្ស។ វាគឺជានិន្នាការគួរឲ្យព្រួយបារម្ភមួយ។

ទាំងនេះ គឺជាការឆ្លុះបញ្ចាំងបឋមមួយចំនួននៅពេលបញ្ចប់ទស្សនៈកិច្ចរយៈពេលពេញមួយសប្តាហ៍របស់ខ្ញុំ។ ខ្ញុំសូមអះអាងសារជាថ្មីចំពោះទស្សនៈរបស់ខ្ញុំថា ការអភិវឌ្ឍន៍ដីធ្លី និងធនធានធម្មជាតិ របស់ប្រទេសកម្ពុជា អាចមានវិជ្ជមាន ប្រសិនបើត្រូវបានធ្វើឡើង តាមលក្ខណៈមួយប្រកបដោយនិរន្តភាព និងសមធម៌។ ក្នុងស្មារតី ស្ថាបនា ខ្ញុំសូមលើកឡើងនូវកង្វល់បឋមទាំងនេះ។

ទាក់ទងនឹងករណីនេះ ខ្ញុំសូមអបអរសារទចំពោះបទបញ្ជា របស់លោកនាយករដ្ឋមន្រ្តី ចុះថ្ងៃទី៧ ខែឧសភា ឆ្នាំ២០១២ ដែលដាក់ឲ្យមានការផ្អាកជាបណ្តោះអាសន្នទៅលើការផ្តល់ដីសម្បទានសេដ្ឋកិច្ចថ្មី និងដាក់ឲ្យមានការពិនិត្យពិច័យយ៉ាងហ្មត់ចត់ទៅលើដីសម្បទានដែលមានរួចហើយ ក្នុងគោលបំណងដើម្បីការពារដល់ផលប្រយោជន៍របស់សហគមន៍។ នេះគឺជាជំហ៊ានដ៏ល្អមួយក្នុងទិសដៅត្រឹមត្រូវ។ ជានិច្ចកាល គេត្រូវយកចិត្តទុកដាក់ទៅលើ ការអនុវត្តបទបញ្ជាថ្មីឲ្យបានខ្ជាប់ខ្ជួន។

បច្ចុប្បន្នកម្ពុជា គឺថិតនៅក្នុងដំណាក់កាលនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ដែលកំណត់កាលបរិច្ឆេទរួចហើយនៅថ្ងៃទី០៣ ខែមិថុនានេះ។ ខ្ញុំបានប្រឹងប្រែងអស់ពីកម្លាំងកាយចិត្ត លើបេសសកម្មចុងក្រោយរបស់ខ្ញុំសំរាប់ប្រទេសនេះ ដោយពិនិត្យទៅលើបញ្ហាសិទ្ធិមនុស្សក្នុងអំឡុងពេលបោះឆ្នោតនេះ ហើយជាថ្មីម្តងទៀត ខ្ញុំសូមគូរបញ្ជាក់ ទៅលើសេចក្តីថ្លែងការណ៍ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១១កន្លងទៅ។ ខ្ញុំក៏សូមធ្វើការអំពាវនាវឡើងវិញ ចំពោះគ្រប់ភាគីទាំងអស់ និងគណៈកម្មការជាតិរៀបចំការបោះឆ្នោត ធ្វើយ៉ាងណាធានាអោយបាននូវការបោះឆ្នោតដោយសេរី យុត្តិធម៌ និងប្រកបដោយសន្តិភាព។

ខ្ញុំក៏សូមថ្លែងអំណរគុណដល់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ដែលបានបន្តការសហការដ៏ល្អជាមួយរូបខ្ញុំ ក្នុងអំឡុងពេលទស្សនកិច្ចនេះ ហើយជាពិសេស អាជ្ញាធរនៅខេត្តរតនៈគីរី ស្ទឹងត្រែង និងក្រចេះ។ ខ្ញុំសូមថ្លែងអំណរគុណដល់សហគមន៍ទាំងឡាយដែលខ្ញុំបានធ្វើទស្សនកិច្ច ចំពោះការស្វាគមន៍យ៉ាងកក់ក្តៅព្រមទាំងដៃគូសន្ទាដ៏ទៃទៀត មានដូចជា សង្គមស៊ីវិល ក្រុមការងារនៃសហប្រជាជាតិប្រចាំនៅកម្ពុជា និងម្ចាស់ជំនួយនានា។ ដូចសព្វដង ការិយាល័យនៃឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សបានផ្តល់ការគាំទ្រដល់ខ្ញុំខាងភស្តុភា និងបច្ចេកទេសដ៏ចំបាច់ ដើម្បីបំពេញការងាររបស់ខ្ញុំ និងសូមអរគុណដល់ពួកគាត់។

**ចប់**

*លោកសាស្ត្រាចារ្យ **សុរិយា ប្រាសាទ ស៊ូប៊ែឌី** ត្រូវបានក្រុមប្រឹក្សាសិទ្ធិមនុស្ស អ.ស.ប តែងតាំងជាអ្នក រាយការណ៍ពិសេសស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា ក្នុងខែមីនា ឆ្នាំ២០០៩។ ក្នុងនាមជាអ្នករាយ ការណ៍ពិសេស លោកមិនចំណុះ រដ្ឋាភិបាល ឬអង្គការណាមួយឡើយ ហើយបំរើការក្នុងសមត្ថភាព បុគ្គលលោកផ្ទាល់ ។ បច្ចុប្បន្នលោក គឺជាសាស្ត្រាចារ្យ ផ្នែកនីតិអន្តរជាតិនៃសាកលវិទ្យាល័យលីដស៍ ចក្រភពអង់គ្លេស។*

*រាល់សំណើព័ត៌មានទាក់ទងនឹងអ្នករាយការណ៍ពិសេស អាចទំនាក់ទំនងមកការិយាល័យឧត្តមស្នងការ អ.ស.ប ទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា។ សូមទំនាក់ទំនងមក កញ្ញា **ហ្សូអ៊ី ឡាធំបូ** (តាមរយៈទូរស័ព្ទលេខ +៨៥៥ ០១២ ៧៩០ ១៧៨/ អ៊ីម៉េល zlatumbo@ohchr.org) ឬ លោក **ទូច ហួន** (ទូរស័ព្ទលេខ +៨៥៥ ០១២ ៤៧៦ ៤៩/ អ៊ីម៉េល htouch@ohchr.org)*